# តើលោកអ្នកត្រូវការ ការធានារ៉ាប់រងសុខភាពដែរឬទេ?

## យើងអាចជួយបាន ។ គ្រាន់តែសាកសួរប៉ុណ្ណោះ ។

ប្រសិនបើលោកអ្នករស់នៅរដ្ឋម៉ាសាជូសេត មានកម្មវិធីធានារ៉ាប់រង សុខភាពថ្មីៗ ដែលអាចទទួលបាន ហើយយើងអាចជួយបាន ។ សូមទាក់ទងយើងនៅថ្ងៃនេះដើម្បីស្វែងយល់ពីរបៀបដាក់ពាក្យសុំ ។



MHA Massachusetts Hospital Association

Massachusetts League of Community Health Centers

Health Care for all — Real change for real people

*ការផ្តល់មូលនិធិសម្រាប់ខិតប័ណ្ណនេះ ត្រូវបានផ្តល់ឱ្យដោយ ការិយាល័យប្រតិបត្តិសេវាកម្មសុខភាព និង មនុស្សរដ្ឋម៉ាសាជូសេត - ២០០៧*

*www.gethealthcoverage.net*

**លោកអ្នកប្រហែលជាអាចទទួលការធានារ៉ាប់រងសុខភាពក្នុងតម្លៃថោក ។**

**មានច្បាប់ថ្មីមួយនៅក្នុងរដ្ឋម៉ាសាជូសេតដែលតម្រូវឱ្យមនុស្សពេញវ័យទាំងអស់ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ មានការធានារ៉ាប់រងសុខភាព ។**

មានកម្មវិធីធានារ៉ាប់រងសុខភាពក្នុងតម្លៃថោកជាច្រើន សម្រាប់មនុស្សពេញវ័យ និង ក្មេងដែលរស់នៅក្នុងរដ្ឋម៉ាសាជូសេត ។ លើសពីនេះ យើងក៏មានជម្រើសថ្មីៗមួយចំនួនដែរ ។ វាមានភាពងាយស្រួលក្នុងការដាក់ពាក្យសុំ ហើយបុគ្គលិករបស់យើងអាចជួយពន្យល់ពីជម្រើសដែលអាចមានសម្រាប់លោកអ្នក ។



### ការធានារ៉ាប់រងអាចរ៉ាប់រងថ្លៃចំណាយនៃ :

- ការទៅជួបវេជ្ជបណ្ឌិត
- ការស្នាក់នៅមន្ទីរពេទ្យ
- ការព្យាបាលសុខភាពផ្លូវចិត្ត, ជាតិស្រវឹង និង ការប្រើថ្នាំញៀន
- ថ្នាំតាមវេជ្ជបញ្ជា
    - ការថែទាំសង្គ្រោះបន្ទាន់

### តើខ្ញុំនឹងត្រូវបង់ប្រាក់ប៉ុន្មាន?

នេះអាស្រ័យលើចំណូលគ្រួសារប្រចាំឆ្នាំរបស់លោកអ្នក ។ ការធានារ៉ាប់រងសុខភាពមួយចំនួនត្រូវការឱ្យលោកអ្នកបង់ប្រាក់ សហការ ( ប្រាក់ដែលលោកអ្នកបង់រាល់ពេលដែលលោកអ្នកប្រើប្រាស់សេវាកម្មសុខភាពជាក់លាក់ផ្សេងៗ) តិចតួចប៉ុណ្ណោះ ។ ការធានារ៉ាប់រងសុខភាពមួយចំនួនទៀតត្រូវការឱ្យលោកអ្នកបង់ប្រាក់ធានាប្រចាំខែ ( ប្រាក់ដែលលោកអ្នកបង់រៀងរាល់ខែ) និង បង់ប្រាក់សហការ ។

### តើខ្ញុំត្រូវយកអ្វីខ្លះមកជាមួយនៅពេលខ្ញុំដាក់ពាក្យសុំ?

- ព័ស្តុតាងនៃចំណូលគ្រួសារប្រចាំឆ្នាំរបស់លោកអ្នក ( បង្កាន់ដៃប្រាក់បៀវត្សរ៍, សុវត្ថិភាពសង្គម, លិខិតពីនិយោជករបស់លោកអ្នក, បង្កាន់ដៃទទួលប្រាក់ពន្ធវិញ ឬ របាយការណ៏ធនាគារ)

- ព័ស្តុតាងនៃសញ្ជាតិ និង អត្តសញ្ញាណ ប្រសិនបើលោកអ្នកគឺជាប្រជាពលរដ្ឋសហរដ្ឋអាមេរិក ( អត្តសញ្ញាណប័ណ្ណមានរូបថត និង សំបុត្រកំណើត ឬ លិខិតឆ្លងដែន)

- អ្នកដែលគ្មានសញ្ជាតិ ត្រូវយកព័ស្តុតាងនៃស្ថានភាពអន្តោប្រវេសន៍ ប្រសិនបើមាន